**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**អគ្គិសនីកម្ពុជា**
**គណៈកម្មាធិការលទ្ធកម្ម**
លេខ: ..៧៣៣....... PC.អក

# សេចក្តីជូនដំណឹង
## ស្តីពី

ការផ្គត់ផ្គង់ សម្ភារសុវត្ថិភាព ចំនួន 02 មុខ សម្រាប់ផ្តល់ជូនជំនាញនៅភ្នំពេញ (រួមទាំងសាខាអគ្គិសនីទាំងបី) នៃនាយកដ្ឋានអាជីវកម្មចែកចាយ និងអង្គភាពអគ្គិសនីខេត្តចំនួន ១៤

អគ្គិសនីកម្ពុជាសូមជូនដំណឹងដល់បណ្តាក្រុមហ៊ុន/សហគ្រាស (គិតទាំងសហគ្រាសឯកត្តបុគ្គល) ទាំងអស់ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាអោយបានជ្រាបថា អគ្គិសនីកម្ពុជា នឹងដាក់អោយដេញថ្លៃជាសាធារណៈ ដើម្បីផ្គត់ផ្គង់ សម្ភារសុវត្ថិភាព ចំនួន 02 មុខ សម្រាប់ផ្តល់ជូនជំនាញនៅភ្នំពេញ (រួមទាំងសាខាអគ្គិសនីទាំងបី) នៃនាយកដ្ឋានអាជីវកម្មចែកចាយ និងអង្គភាពអគ្គិសនីខេត្តចំនួន ១៤ ។

អគ្គិសនីកម្ពុជា បានរៀបចំឯកសារសម្រាប់ក្រុមហ៊ុន/សហគ្រាសបំពេញដើម្បីចូលរួមដេញថ្លៃ និងមានដាក់លក់នៅអង្គភាពលទ្ធកម្មអគ្គិសនីកម្ពុជា ដែលមានអាសយដ្ឋាន: អាគារលេខ២ ផ្លូវព្រះយុគន្ធរ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញចាប់ពីថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៨ តទៅរៀងរាល់ម៉ោងធ្វើការ (ទូរស័ព្ទទាក់ទងលេខ៖ 023 67 66 007 និង Website: www.edc.com.kh ) ។

កាលបរិច្ឆេទឈប់ទទួលសំណើដេញថ្លៃ នៅម៉ោង ១៤:០០ ថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៨ ។

ការបើកសំណើដេញថ្លៃ នឹងប្រព្រឹត្តទៅនៅអង្គភាពលទ្ធកម្ម តាមអាសយដ្ឋាន ខាងលើវេលាម៉ោង ១៥:០០ ថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៨ ។

ក្រុមហ៊ុន/សហគ្រាសដែលមានសម្ព័ន្ធភាពជាមួយគ្នាឬមានប្រភពតែមួយអាចដាក់សំណើដេញថ្លៃបានតែមួយគត់។

ក្រុមហ៊ុន/សហគ្រាសដែលមានបំណងចូលរួមដេញថ្លៃ សូមអញ្ជើញទាក់ទងជាមួយអង្គភាពលទ្ធកម្ម ដើម្បីទិញឯកសារដេញថ្លៃ និងសាកសួរព័ត៌មាន ដែលទាក់ទងនឹងការដេញថ្លៃនេះ ។

ថ្ងៃ សុក្រ ១២ កើត ខែ ផល្គុន ឆ្នាំរកា នព្វស័ក ព.ស ២៥៦១
រាជធានីភ្នំពេញ, ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ២០១៨
**ប្រធានគណៈកម្មាធិការលទ្ធកម្ម**

**ឆិន-អ៊ីង**

ចម្លងជូន៖
-អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ
-អង្គភាពប្រឆាំងអំពើពុករលួយ